"ធនាគារជាតិនៃកម្ពុជា មានមោទនភាពយ៉ាងក្រៃលែងដែលបានចូលជាសមាជិកពេញលេញរបស់សហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៥ កន្លងមក ។ ការចូលជាសមាជិករបស់សហព័ន្ធនេះ គឺស្របតាមបេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា និងការទទួលស្គាល់អំពីសារៈសំខាន់នៃបរិយាប័ន្នហិរញ្ញវត្ថុ ព្រមទាំងតួនាទីរបស់សហព័ន្ធបរិយាប័ន្នហិរញ្ញវត្ថុ (ហៅកាត់ថា AFI) ក្នុងការលើកកម្ពស់នូវសុចរិតភាពនិងស្ថិរភាពហិរញ្ញវត្ថុ ទាំងកម្រិតថ្នាក់ជាតិនិងពិភពលោក ក៏ដូចជា ការចូលរួមចំណែកដល់កំណើនដែលប្រកបដោយភាពរឹងមាំនិងបរិយាប័ន្នភាព នៅបណ្តាសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍និងកំពុងងើបឡើងវិញ" ។